# ការចម្រើនលូតលាស់ជំនាញផ្នែកប្រាស្រ័យទាក់ទងរបស់កូនក្មេងអាយុ០-៣ឆ្នាំ

## គឺចំនួននៃការនិយាយធម្មតាជារៀងរាល់ថ្ងៃដែលលោកអ្នកចែករំលែកជាមួយកូនលោកអ្នក ដែលមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់ឲ្យកុមាររៀនបានពូកែនៅសាលា ទោះបីជានៅមុនពេលកូនរបស់លោកអ្នកចេះនិយាយស្ដីក្ដី។

ទារក និងកូនក្មេងតូចៗរៀនប្រាស្រ័យទាក់ទងគ្នា (បញ្ជូន និងទទួលសារជាមួយមនុស្សដទៃ) ដែលមានយូរណាស់មកហើយ មុននឹងគេរៀនចេះនិយាយ។ គេរៀនប្រាស្រ័យទាក់ទងនៅក្នុងអម្លុងពេលទាក់ទងប្រចាំថ្ងៃជាមួយមនុស្សនៅជុំវិញគេ។ គេមើល និងស្ដាប់អ្នកដទៃ ក្នុងកាលគេប្រើកាយវិការដើម្បីសម្ដែងអំពីសេចក្ដីត្រូវការ ការមានអារម្មណ៍ និងបទពិសោធន៍របស់គេ។

ការមានជំនាញផ្នែកប្រាស្រ័យទាក់ទងបានល្អទាន់ពេល នាំឲ្យគេចេះភាសា និងចេះអក្សរបានល្អ (ការអាន និងការសរសេរ)។

ទារកជាប្រចាំ តែងតែ:
ស្ដាប់ - ទោះបីជាគេនៅក្នុងស្បូនក្ដី
សម្លឹងមើល – មើលឲ្យចំភ្នែក គឺជាការសំខាន់ជាខ្លាំងមុនពេលកូនក្មេងចេះនិយាយ
ការធ្វើមុខក្រម៉ាច់ក្រម៉ើម - ញាក់មុខញាក់មាត់ធ្វើឲ្យកូនក្មេងចាប់អារម្មណ៍

## ការធំលូតលាស់ខួរក្បាល

បីឆ្នាំដំបូងនៃជីវិតរបស់កូនលោកអ្នក គឺជាពេលដែលខួរក្បាលរបស់គេរីកធំ និងលូតលាស់លឿនជាងពេលណាទាំងអស់នៅក្នុងជីវិតរបស់គេ។

នេះគឺជាពេលសំខាន់ផងដែរសំរាប់ខួរក្បាលរបស់កូនលោកអ្នករៀនមើល និងស្ដាប់ឮ។ ទារកត្រូវការមើលឲ្យឃើញចលនា រូបរាង ពណ៌ និងវត្ថុ (ចូលមកជិត និងទៅឆ្ងាយ) ដើម្បីឲ្យខួរក្បាលរបស់គេរៀនចេះអំពីរបៀបមើលឃើញ។ ទារកក៏ត្រូវការស្ដាប់ឮសម្លេងជាច្រើនខុសៗគ្នាដែរដើម្បីធ្វើឲ្យចម្រើនលូតលាស់ដល់ការស្ដាប់ និងការយល់ដឹងរបស់គេអំពីសម្លេង។

ពេលសំខាន់សំរាប់ការរីកចម្រើនខាងភាសា និងការរៀននិយាយគឺនៅក្នុងពីរ-បីឆ្នាំដំបូងនៃជីវិតរបស់គេ។ កូនក្មេងត្រូវការស្ដាប់ឮលោកអ្នកនិយាយ ច្រៀង និងអានឲ្យគេស្ដាប់គ្រប់ពេល។ គេក៏ត្រូវការឲ្យលោកអ្នកនិយាយទៅកាន់គេផងដែរ ពេលណាគេកំពុងនិយាយកកេរកករ និងខិតខំចម្លងតាមការប្រាស្រ័យទាក់ទងរបស់លោកអ្នក។

## លោកអ្នកគឺជាគ្រូបង្ហាត់ទីមួយ និងសំខាន់បំផុតរបស់កូនលោកអ្នក

- ស្ដាប់កូនរបស់លោកអ្នក
- និយាយជាមួយកូនរបស់លោកអ្នក
- ច្រៀងចំរៀង និងសូត្រពាក្យចុងចួនជាមួយគ្នា
- អានសៀវភៅជាមួយគ្នា
- ទៅទីកន្លែងណាដែលថ្មីជាមួយគ្នា
- ឲ្យគេនូវវត្ថុខុសៗគ្នាសំរាប់លេងដែលមានក្នុងផ្ទះ
- ប្រាប់ឲ្យគេដឹងថាគេធ្វើបានល្អ

សូមចងចាំ:
ការលេងជាមួយកូនក្មេង គឺបង្រៀនគេឲ្យចេះប្រាស្រ័យទាក់ទងគ្នា។ ទូរទស្សន៍ និងល្បែងលេង និងកម្មវិធីខុមព្យូធើរ ឌីវីឌី និងសន្លឹកបៀរដែលមានរូប ទោះបីវាជារបស់សំរាប់អប់រំក្ដី នឹងពុំបានជួយកូនក្មេងធ្វើឲ្យចម្រើនលូតលាស់ដល់ការប្រាស្រ័យទាក់ទងរបស់គេឡើយ។ មានតែការនិយាយជាមួយមនុស្សប៉ុណ្ណោះ ដែលកូនក្មេងអាចចម្រើនលូតលាស់ការប្រាស្រ័យទាក់ទងរបស់គេ។

